**ឯកសារស្រាវជ្រាវសង្ខេប**

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី ៨

# ការចុះបញ្ជីដីធ្លីសមូហភាពរបស់សហគមន៍ជនជាតិដើម ភាគតិចនៅក្នុងខេត្តរតនគិរី

រៀបចំដោយៈ លោក ខាំ វ៉ាន់ដា
លោក នន់ អស្សាច័ន្ទ
លោកស្រី ជា ម៉ាលីកា
កញ្ញា រីន ម៉ូម៉ូថាយ

ខែមេសា ឆ្នាំ២០១៦

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា) វ.ស.ក (គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបសសមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាងឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃគេហទំព័រនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារនៅក្នុងគេហទំព័រនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៦ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)

# មាតិកា

**១សេចក្តីផ្តើម** . 1

**២គោលនយោបាយរបស់រដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តិទាក់ទងនឹងសហគមន៍ . ជនជាតិដើមភាគតិច** 1

២ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយសម្រាប់គាំទ្រដល់សហគមន៍ជនជាតិដើមភាគតិច .១. 1

២នីតិវិធីសំខាន់ៗនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច .២. 3

**៣ការចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច និងបញ្ហាប្រឈមក្នុងខេត្ត . រតនៈគីរី** 4

៣ការចុះបញ្ជីដីសមូ .១.ហភាពសហគមន៍ជនជាតិដើមភាគតិច 5

៣បញ្ហាប្រឈមការចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច .២. 7

**៤. សន្និដ្ឋាន** 8

**៦កសារយោង** 9

# ១. សេចក្តីផ្តើម

នៅក្នុងប្រទេសកម្ពុជា ជនជាតិដើមភាគតិចមានចំនួន២៣ក្រុម[1] (ប្រមាណជា ២00,000នាក់) កំពុងរស់នៅតាមបណ្តាខេត្តនៅភាគឦសាននៃប្រទេស ដូចជា ខេត្តរតនគិរី(៥៩%) មណ្ឌលគិរី (៤៩%) ក្រចេះ(១២%) និងស្ទឹងត្រែង (១0%) នៃចំនួនប្រជាជនសរុបនៅក្នុងខេត្តនីមួយៗ។[2] ការរស់នៅរបស់ពួកគេពឹងផ្អែកយ៉ាងខ្លាំងទៅលើផល និងអនុផលព្រៃឈើដែលនៅជុំវិញ។ បើទោះជាការអភិវឌ្ឍអាចនឹងធ្វើអោយការរស់នៅរបស់ពួកគាត់មានការផ្លាស់ប្តូរយ៉ាងក៏ដោយ ក៏ដីធ្លីនៅតែមានសារៈសំខាន់សម្រាប់ការរស់នៅ ការរៀបចំសង្គម និងអត្តសញ្ញាណរបស់ជនជាតិដើមភាគតិច។[3] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់សិទ្ធិស្មើៗគ្នាដល់ប្រជាជនកម្ពុជាទាំងអស់ ដោយមិនប្រកាន់ជាតិសាសន៍ណាមួយឡើយ។ ខណៈដែលច្បាប់ភូមិបាល២00១ ផ្តល់នូវឱកាសដល់ជនជាតិដើមភាគតិចក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន ជាមួយគ្នានឹងសិទ្ធិដីធ្លីជាសមូហភាពរបស់ជនជាតិដើមភាគតិច[4] គេសង្កេតឃើញថា នៅមានគោលនយោបាយសំខាន់ៗដទៃទៀត ត្រូវបានបង្កើតឡើងដើម្បីធានាសិទ្ធិកាន់កាប់កម្មសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច។ គោលនយោបាយ និងច្បាប់ទាំងនេះរួមមានៈ (១) គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចឆ្នាំ២00៩ (២) អនុក្រឹត្យស្តីពី នីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។ ទោះបីជារដ្ឋាភិបាលខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាការចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិចយ៉ាងណាក៏ដោយ គេសង្កេតឃើញថាស្ថានភាពនៃការចុះបញ្ជីដីធ្លីត្រូវបានគេមើលឃើញថានៅមានការយឺតយ៉ាវនៅឡើយ។[5]

ឯកសារស្រាវជ្រាវសង្ខេបនេះ[6] នឹងពិភាក្សាដោយសង្ខេបអំពីគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលមានស្រាប់ និងឯកសារច្បាប់ដែលពាក់ព័ន្ធនឹងសហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា។ ឯកសារនេះ ក៏នឹងផ្តល់នូវទិដ្ឋភាពទូទៅអំពីស្ថានភាព និងបញ្ហានានាទាក់ទងនឹងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចនៅក្នុងខេត្តរតនគិរី។ ឯកសារនេះ ក៏នឹងផ្តល់នូវមតិកែលំអមួយចំនួនដើម្បីដោះស្រាយបញ្ហាការចុះបញ្ជីដីធ្លីសមូហភាពនេះផងដែរ។

# ២. គោលនយោបាយរបស់រដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តិទាក់ទងនឹងសហគមន៍ជនជាតិដើមភាគតិច

## ២.១. ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយសម្រាប់គាំទ្រដល់សហគមន៍ជនជាតិដើមភាគតិច

ដូចគ្នានឹងប្រជាជនកម្ពុជាទូទៅដែរ សិទ្ធិរបស់ជនជាតិដើមភាគតិចត្រូវបានធានាដោយច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។[7] លើសពីនេះ សិទ្ធិរបស់ពួកគាត់ត្រូវបានចែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ២00១ និងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចឆ្នាំ២00៩ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀត។[8][9] ច្បាប់ភូមិបាលបានបញ្ចូលសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច នៅក្នុងផ្នែកទី២នៃ

ជំពូកទី៣ អំពី "អចលនវត្ថុរបស់ជនជាតិដើមភាគតិច"។ ផ្នែកដដែលនោះក៏បានកំណត់ "សហគមន៍ជនជាតិដើមភាគតិចមួយ" ជា "*ក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គម វប្បធម៌ និងសេដ្ឋកិច្ច និងប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព*"។[10] លើសពីនេះទៀត ច្បាប់ភូមិបាលក៏បានផ្តល់នូវការពន្យល់ដ៏ជាក់លាក់មួយ អំពីកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ទាក់ទងនឹងកម្មសិទ្ធិដីធ្លីជាសមូហភាព (សូមមើលព័ត៌មានលម្អិតនៅក្នុងមាត្រា២៦)។[11] ការអនុវត្តសិទ្ធិស្តីពីកម្មសិទ្ធិទាក់ទងនឹងអចលនទ្រព្យរបស់សហគមន៍ជនជាតិដើមភាគតិច និងលក្ខខណ្ឌជាក់លាក់មួយចំនួននៃការប្រើប្រាស់ដីធ្លី គឺស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរប្រពៃណី និងយន្តការនៃការធ្វើសេចក្តីការសម្រេចចិត្តរបស់សហគមន៍ គឺអនុលោមទៅតាមការប្រណិប័តន៍ប្រពៃណីរបស់ពួកគាត់។ កម្មសិទ្ធិសមូហភាពមានន័យថា រាល់សិទ្ធិនិងសិទ្ធិការពាររបស់សហគមន៍ជនជាតិដើមភាគតិចគឺដូចគ្នាទៅនឹងកម្មសិទ្ធិឯកជនដែរ។ ទោះបីជាយ៉ាងណាក៏ដោយ សហគមន៍ជនជាតិដើមភាគតិច មិនមានសិទ្ធិចាត់ចែងដីធ្លីដែលជាសម្បត្តិរដ្ឋ ហើយជាកម្មសិទ្ធិសមូហភាព ទៅឲ្យបុគ្គលណាម្នាក់ ឬក្រុមណាមួយបានឡើយ។[12]

បន្ថែមលើច្បាប់ភូមិបាល ២០០១ រដ្ឋាភិបាលកម្ពុជាក៏បានបង្កើតគោលនយោបាយជាតិស្តីពី ការអភិវឌ្ឍជនជាតិដើមភាគតិចនៅក្នុងឆ្នាំ២០០៩។ គោលនយោបាយនេះមានគោលបំណងផ្តល់ការគាំទ្រដើម្បីធានាថាការអភិវឌ្ឍរបស់កម្ពុជាចូលរួមធ្វើឲ្យប្រសើរឡើងដល់សហគមន៍ជនជាតិដើមភាគតិច។ គោលនយោបាយជាតិស្តីពី ការអភិវឌ្ឍជនជាតិដើមភាគតិចនៅក្នុងឆ្នាំ២០០៩នេះ បានដាក់ចេញនូវគោលនយោបាយតាមវិស័យជាច្រើន សម្រាប់ផ្តល់ការគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិច ដូចជាវិស័យវប្បធម៌ អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សុខភាព បរិស្ថាន ការកាន់កាប់ដីធ្លី កសិកម្ម ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ យុត្តិធម៌ ទេសចរណ៍ និងឧស្សាហកម្មរ៉ុករករ៉ែ។[13]

ទាក់ទងទៅនឹងវិស័យភូមិបាល ចំណុចសំខាន់មួយចំនួននៃគោលនយោបាយសម្រាប់ការគាំទ្រដល់ការកាន់កាប់ដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ដែលមានចែងក្នុងគោលនយោបាយ២០០៩ មានភាពស៊ីសង្វាក់គ្នាទៅនឹងមាត្រាមួយចំនួន (ដូចជាមាត្រា២៥ ស្តីពីវិសាលភាពដីធ្លី និង មាត្រា២៦ ស្តីពីទស្សនាទាននៃកម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច) នៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១។[14] ភាពស៊ីសង្វាក់នេះ ទំនងអាចជួយពង្រឹងសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ជាពិសេសការចុះបញ្ជីលើកម្មសិទ្ធិដីសមូហភាព។

នៅឆ្នាំ២០០៩ អនុក្រឹត្យស្តីពី នីតិវិធីចុះបញ្ជីដីរបស់សហគមន៍ជនជាតិភាគតិច (ឬអនុក្រឹត្យ៨៣) ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល។ អនុក្រឹត្យនេះ កំណត់ប្រភេទដីដែលអាចចុះបញ្ជីជាកម្មសិទ្ធិសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិច ប្រភេទដីទាំងនេះរួមមានៈ[15]

**១. ដីឯកជនរបស់រដ្ឋ** (ក) ដីលំនៅដ្ឋាន (ខ) ដីសម្រាប់ដាំដុះ និង

**២. ដីសាធារណៈរបស់រដ្ឋ ដែលបានចុះបញ្ជីជាមួយរដ្ឋ** (ក) ដីទុកបំរុងសម្រាប់ការដាំដំណាំវិលជុំ (shifting cultivation) (សរុបមិនអោយលើសពី ៧ហិចតា) (ខ) ដីព្រៃអារក្ស (spiritual forest land), និង (គ) ដីកប់ខ្មោច (សរុបមិនអោយលើសពី ៧ហិចតា)

អនុក្រឹត្យ៨៣ ក៏បានបង្ហាញពីនីតិវិធី និងយន្តការសម្រាប់ការចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ដែលនឹងសង្ខេបនៅផ្នែកទី ២.២. ខាងក្រោម។

## ២.២. នីតិវិធីសំខាន់ៗនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច

នៅក្នុងអនុក្រឹត្យ៨៣ (ស្តីពី នីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច) ដំណើរការសម្រាប់ចុះបញ្ជីដីធ្លីដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ហាក់ដូចជាមានលក្ខណៈស្មុគស្មាញ និងមានរយៈពេលយូរ។ ជាក់ស្តែង សហគមន៍ជនជាតិដើមភាគតិច ត្រូវបានគេតម្រូវឲ្យបំពេញនូវដំណាក់កាលបីសំខាន់ៗ ព្រមទាំងជំហានផ្សេងៗនៅក្នុងដំណាក់កាលនីមួយៗ ដើម្បីទទួលបាននូវកម្មសិទ្ធិដីធ្លីសមូហភាព (collective land title)។ ដំណាក់កាលបីសំខាន់ៗនោះរួមមាន៖[16][17]

(១) សហគមន៍ជនជាតិដើមភាគតិច ត្រូវទទួលបានការកំណត់អត្តសញ្ញាណជាផ្លូវការ ថាជា "សហគមន៍ដែលមានទំនៀមទំលាប់ប្រពៃណី" ពីក្រសួងអភិវឌ្ឍន៍ជនបទ

(២) បន្ទាប់មក សហគមន៍ជនជាតិដើមភាគតិចត្រូវដាក់ពាក្យសុំការទទួលស្គាល់ជា "នីតិបុគ្គល" ជាមួយក្រសួងមហាផ្ទៃ និង

(៣) ជាចុងក្រោយ សហគមន៍ជនជាតិដើមភាគតិចត្រូវបញ្ជូនសំណើសុំការចុះបញ្ជីកម្មសិទ្ធិដីធ្លីសមូហភាព ទៅកាន់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាព។

**រូបភាព១៖ ដំណើរការនៃការចុះបញ្ជីកម្មសិទ្ធិដីធ្លីសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិច**

| "សហគមន៍ដែលមានទំនៀមទំលាប់ប្រពៃណី" ទទួលស្គាល់ដោយក្រសួងអភិវឌ្ឍន៍ជនបទ | ជានីតិបុគ្គលទទួលស្គាល់ដោយក្រសួងមហាផ្ទៃ | បាន ប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាព ចេញដោយក្រសួងរៀបចំដែនដី |
|---|---|---|
| ក្រសួង អភិវឌ្ឍន៍ជនបទ កំណត់ និងចេញនូវសេចក្តីសម្រេចទទួលស្គាល់ជាសហគមន៍ដែលមានទំនៀមទំលាប់ប្រពៃណី ដោយឆ្លងកាត់នូវជំហានដូចខាងក្រោម៖<br>១) អប់រំប្រជាជនពាក់ព័ន្ធនឹងឯកសារចាំបាច់សម្រាប់ការចុះបញ្ជី<br>២) ការកំណត់អត្តសញ្ញាណដោយខ្លួនឯង៖ ប្រជាជនប្រកាសពីក្រុមជនជាតិរបស់ពួកគាត់<br>៣) ការវាយតម្លៃលើអត្តសញ្ញាណ និងការបញ្ជាក់ពី ក្រសួងអភិវឌ្ឍន៍ជនបទ<br>៤) រៀបចំសេចក្តីព្រាងលក្ខន្តិកៈសហគមន៍ និងបញ្ជីរាយនាមរបស់អាជ្ញាធរប្រពៃណី និងការអនុវត្តនានា<br>៥) ការពិគ្រោះយោបល់ដើម្បីរៀបចំឯកសារផ្សេងៗសម្រាប់ដាក់ស្នើទៅកាន់ក្រសួងអភិវឌ្ឍន៍ជនបទ | ក្រសួងមហាផ្ទៃ ទទួលខុសត្រូវ ក្នុងការចេញនូវសេចក្តីសម្រេចទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គល តាមរយៈដំណើរដូចខាងក្រោម៖<br>១) សហគមន៍ជនជាតិដើមភាគតិច ពិនិត្យលក្ខន្តិកៈរបស់ខ្លួន តាមរយៈការបង្កើតឲ្យមានក្រុមការងារ<br>២) រៀបចំកិច្ចប្រជុំពេញអង្គ ដោយមានការចូលរួមពីសមាជិកសហគមន៍ទាំងអស់ និងមន្ត្រីមូលដ្ឋាន (តំណាងថ្នាក់ឃុំ ស្រុក និងខេត្ត) និងតំណាងពីក្រសួងពាក់ព័ន្ធនានាសម្រាប់ការយល់ព្រម<br>៣) បន្ទាប់ពីមានការយល់ព្រមពីក្រុមប្រឹក្សាឃុំ ស្រុក និងអភិបាលខេត្ត រួចមក ក្រសួង មហាផ្ទៃ គឺជាអ្នកសម្រេចចិត្តចុងក្រោយ ក្នុងទទួលស្គាល់សហគមន៍ ជានីតិបុគ្គល។ | ក្រសួងរៀបចំដែនដី ទទួលខុសត្រូវក្នុងការចុះបញ្ជីកម្មសិទ្ធិដីធ្លីសមូហភាព ក្នុងករណីមិនមានជម្លោះដីធ្លីកើតមានឡើង។ លក្ខខណ្ឌនៃការដាក់ពាក្យស្នើសុំក្នុងការចុះបញ្ជីដីធ្លីមានដូចខាងក្រោម៖<br>១) ពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ដោយមានផ្តិតមេដៃរបស់គណៈកម្មាធិការសហគមន៍<br>២) លិខិតប្រគល់សិទ្ធជាតំណាងសហគមន៍សម្រាប់ដំណើរការចុះបញ្ជី ប្រសិនបើប្រធានគណៈកម្មាធិការសហគមន៍មិនបានចូលរួម<br>៣) លក្ខន្តិកៈរបស់សហគមន៍ និងបញ្ជីរាយនាមសមាជិកសហគមន៍មានសេចក្តីបញ្ជាក់ពីចៅសង្កាត់ មេឃុំ<br>៤) បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ ទាក់ទងនឹងរបៀបគ្រប់គ្រង និងការប្រើប្រាស់ដីជាសមូហភាព<br>៥) លិខិតជូនដំណឹងស្តីពីការយល់ព្រមឲ្យចុះបញ្ជីសហគមន៍ដោយក្រសួងមហាផ្ទៃ<br>៦) សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ស្តីពីការតែងតាំងគណៈកម្មាធិការសហគមន៍។ |

# ៣. ការចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច និងបញ្ហាប្រឈមក្នុងខេត្តរតនៈគីរី

ប្រជាជនប្រមាណ ១៨៣,០៩២នាក់ ( ៩០,៩៤៧ នាក់ជាស្ត្រី) និងក្រុមជនជាតិដើមភាគតិចចំនួន ៨ (ទំពួន "៨០១៩ គ្រួសារ" គ្រឿង "៦១៧៥ គ្រួសារ" ចារាយ "៦០០៣ គ្រួសារ" ព្រៅ "២៥៤២ គ្រួសារ" កាចក "៨៤០ គ្រួសារ" ការិត "៥៨៨ គ្រួសារ" ពូនង "១៣៩ គ្រួសារ" និងឡុន "២២០ គ្រួសារ") កំពុងរស់នៅក្នុងខេត្តរតនគីរី[18][19] ហើយជនជាតិដើមភាគតិចទាំងអស់នេះមានចំនួនប្រមាណជា ៥៩% នៃប្រជាជនសរុបក្នុងខេត្តនេះ។[20] បច្ចុប្បន្ន មានសហគមន៍ជនជាតិដើមភាគតិចចំនួន៨១ ក្នុងខេត្តរតនៈគីរី។[21] យោងលើព័ត៌មានក្នុងគេហទំព័ររបស់ GIZ មានសហគមន៍ជនជាតិ

ដើមភាគតិចចំនួនប្រមាណ ៤៥០សហគមន៍ទូទាំងប្រទេស។[22] ផ្នែកខាងក្រោម នឹងបង្ហាញពីស្ថានភាពចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិច ក៏ដូចជាបញ្ហាប្រឈមមួយចំនួនផងដែរ។

### ៣.១. ការចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច

ដើម្បីដោះស្រាយវិវាទរវាងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច និងប្រជាជនក្នុងភូមិ ក៏ដូចជាការជំរុញដំណើរការចុះបញ្ជីដីធ្លី និងការផ្តល់កម្មសិទ្ធិដីធ្លី រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឲ្យមានបទបញ្ជា ០១ ដែលមានការចូលរួមពីយុវជនស្ម័គ្រចិត្ត និងស្ថាប័នពាក់ព័ន្ធក្នុងការធ្វើយុទ្ធនាការផ្តល់កម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ។[23] ស្របជាមួយនឹងបទបញ្ជា០១ នេះ រាជរដ្ឋាភិបាលក៏បានចេញសេចក្តីណែនាំនានា (មានដូចជាសេចក្តីណែនាំលេខ ១៥ ចេញថ្ងៃទី០៤ កក្កដា ២០១២ និងសេចក្តីណែនាំលេខ ១៧ ចេញថ្ងៃទី១៣ កក្កដា ២០១២) ដើម្បីជំរុញការអនុវត្តការចុះបញ្ជីកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិចឲ្យកាន់តែមានប្រសិទ្ធិភាព។[24] រាជរដ្ឋាភិបាល ជាពិសេសការិយាល័យរៀបចំដែនដី នគរូបនីយកម្មសំណង់ និងភូមិបាលក្រុង ស្រុក បានខិតខំបំពេញការងារចុះបញ្ជីកម្មសិទ្ធិដីសមូហភាពបានរហូតដល់ ១០សហគមន៍ ក្នុងរយៈពេល១ឆ្នាំ ក្នុងដំណាក់កាលចុងក្រោយនៃដំណើរការនេះ។[25]

ជាលទ្ធផល និងយោងលើបញ្ជីតារាងបច្ចុប្បន្នភាពរបស់អង្គការ ILO មានសហគមន៍ជនជាតិដើមភាគតិចចំនួន ១៦៦ បានចាប់ផ្តើមរៀបចំចុះកម្មសិទ្ធិដីសមូហភាព។ សហគមន៍ ១១៤ បានបញ្ចប់ដំណាក់កាលទី១ ដោយបានការទទួលស្គាល់ពីក្រសួងអភិវឌ្ឍន៍ជនបទ និងសហគមន៍១៦ ទៀត បានទទួលកម្មសិទ្ធិដីសមូហភាព។[26] ដោយសារតែ សហគមន៍ជនជាតិដើមភាគតិច ត្រូវតែបំពេញតម្រូវការនានាទៅតាមលក្ខខណ្ឌ ក្នុងដំណាក់កាលដំបូងឲ្យបានត្រឹមត្រូវមុននឹងឈានបន្តទៅដំណាក់កាលបន្ទាប់ ហេតុដូចនេះ ការពន្យាផ្សេងៗក្នុងដំណាក់កាលដំបូងនៃការដំណើរការចុះបញ្ជី អាចធ្វើឲ្យដំណើរការចុះបញ្ជីកាន់តែមានរយៈពេលយូរ។ យោងលើព័ត៌មានរបស់ការិយាល័យរៀបចំដែនដីនគរូបនីយ-កម្ម សំណង់ និងភូមិបាលក្រុង ស្រុក និងដូចដែលបានលើកឡើងនៅក្នុង Cambodian Center for Human Rights (CCHR) (2016) ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក បានទទួលពាក្យស្នើសុំកម្មសិទ្ធិដីសមូហភាពពីសហគមន៍ចំនួន ៤៣ ហើយក្នុងនោះ សហគមន៍ចំនួន ១១ ត្រូវបានផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីរួចរាល់ហើយ ចំណែកឯសហគមន៍ចំនួន៩ ទៀត នឹងទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅអំឡុងឆ្នាំ ២០១៦។[27] នេះអាចបង្ហាញថាការស្នើសុំចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច ទំនងជាមានភាពយឺតយ៉ាវនៅ ពីរដំណាក់កាលដំបូងនៃការចុះបញ្ជី។[28]

ជាមួយនឹងការចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តរតនគិរី មានសហគមន៍ ៥៧ ក្នុងចំណោម ៦០ ដែលបានស្នើសុំមកក្រសួងអភិវឌ្ឍន៍ជនបទត្រូវបានទទួលស្គាល់ថាជាសហ-គមន៍ដែលមានប្រពៃណីជនជាតិដើមភាគតិច។ លើសពីនេះទៀត ក្រសួងមហាផ្ទៃបានទទួលស្គាល់សហគមន៍ចំនួន៤៧ ក្នុង ចំណោម ៥៧ ដែលបានស្នើមកក្រសួង ជានីតិបុគ្គល។[29] ចំណែកឯ តារាង

បច្ចុប្បន្នភាពរបស់អង្គការ ILO ស្តីពីការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចបានបង្ហាញថា មានតែ ៦សហគមន៍ ក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចចំនួន១៦ ប៉ុណ្ណោះ ដែលទទួលបានកម្មសិទ្ធិដីសមូហភាព (៥នៅស្រុកអូរជុំ និង១នៅស្រុកកូនមុំ)។

**តារាង១៖ ស្ថានភាពនៃការចុះបញ្ជីដីធ្លីសមូហភាពរបស់ជនជាតិដើមភាគតិច**

| ល.រ | ស្រុក | ចំនួនសហគមន៍ជនជាតិដើមភាគតិច | ក្រសួងអភិ.ជនបទ | | ក្រសួង មហាផ្ទៃ | | ក្រសួង រៀបចំដែនដី | |
|---|---|---|---|---|---|---|---|---|
| | | | ដាក់ពាក្យ | ទទួលស្គាល់ | ដាក់ពាក្យ | ទទួលស្គាល់ | ដាក់ពាក្យ | ទទួលប័ណ្ណ |
| 1 | បរកែវ | 10 | 8 | 7 | 8 | 7 | - | - |
| 2 | អូយ៉ាដាវ | 12 | 10 | 10 | 8 | 8 | 1 | - |
| 3 | អណ្តូងមាស | 11 | 11 | 9 | 5 | 2 | - | - |
| 4 | អូរជុំ | 15 | 11 | 11 | 14 | 12 | 10 | 5 |
| 5 | កូនមុំ | 5 | 4 | 4 | 5 | 2 | 1 | 1 |
| 6 | បានលុង | 0 | 0 | 0 | 0 | 0 | 0 | - |
| 7 | លំផាត់ | 13 | 9 | 9 | 8 | 7 | 3 | - |
| 8 | តាវែង | 6 | 5 | 5 | 5 | 5 | 1 | - |
| 9 | វើនសៃ | 9 | 2 | 2 | 4 | 4 | - | - |
| | **សរុប** | **81** | **60** | **57** | **57** | **47** | **16** | **6** |

Source: ILO, "Update list of collective land titling progress with support of ILO, GIZ, NGO, and target affected by Directive 01 from 2003-13/01/2015. "

តារាង១ បង្ហាញថាសហគមន៍ជនជាតិដើមភាគតិចនៅស្រុកបរកែវ អូរយ៉ាដាវ និងអណ្តូងមាសពុំទាន់បានទទួលកម្មសិទ្ធិដីសមូហភាពពីការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុកនៅឡើយទេ។ ដោយហេតុថាមានតែសហគមន៍ជនជាតិដើមភាគតិចតែ១គត់ នៅស្រុកអូរយ៉ាដាវដែលបានស្នើសុំកម្មសិទ្ធិដីសមូហភាពពីការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក[30] ហើយក៏ប្រហែលកំពុងស្ថិតនៅក្នុងដំណើរការវាយតម្លៃពាក្យស្នើសុំដែរ។ ក្រាហ្វិក១ ក៏បានបង្ហាញពី សហគមន៍ជនជាតិភាគដើមភាគតិចចំនួន ៧នៅស្រុកបរកែវ ១០នៅអូរយ៉ាដាវ និង៩នៅអណ្តូងមាស ដែលត្រូវបានទទួលស្គាល់ដោយក្រសួងអភិវឌ្ឍន៍ជនបទ ថាជាសហ-គមន៍ប្រពៃណីជនជាតិដើម។ ចំណែកឯក្រសួងមហាផ្ទៃវិញ ក៏បានទទួលស្គាល់សហគមន៍ជនជាតិដើមជានីតិបុគ្គលជាច្រើនដែរ មាននៅស្រុកបរកែវចំនួន៧សហគមន៍ ៨នៅអូរយ៉ាដាវ និង២១ នៅអណ្តូងមាស។ អ្នកនិពន្ធឯកសារនេះ ពុំអាចរកឃើញពីមូលហេតុច្បាស់លាស់ដែលធ្វើឲ្យ សហគមន៍ជនជាតិដើមនៅស្រុកអណ្តូងមាសបានទទួលស្គាល់ថាជា នីតិបុគ្គលតិចជាងស្រុកដ៏ទៃដែលអនុញ្ញាតដោយក្រសួងមហាផ្ទៃនោះទេ។

**ក្រាហ្វិក ១៖ ចំនួនសហគមន៍ជនជាតិដើមភាគតិចដែលបានទទួលស្គាល់ដោយក្រសួងអភិវឌ្ឍន៍ជនបទ និង ក្រសួងមហាផ្ទៃនៅស្រុក អណ្ដូងមាស អូរយ៉ាដាវ និងបរកែវ**




Source: ILO, "Update list of collective land titling progress with support of ILO, GIZ, NGO, and target affected by Directive 01 from 2003-13/01/2015. "

### ៣.២. បញ្ហាប្រឈមការចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច

តាមរយៈការអនុវត្តបទបញ្ជា ០១ ការចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចមានវឌ្ឍន-ភាពគួរឲ្យកត់សម្គាល់ ប៉ុន្តែគេក៏បានសង្កេតឃើញថា សហគមន៍ជនជាតិដើមភាគតិចជួបបញ្ហា និង បញ្ហាប្រឈមមួយចំនួនផងដែរក្នុងការចុះបញ្ជីកម្មសិទ្ធិដីសមូហភាព។ បញ្ហាទីមួយ គឺបញ្ហាពាក់ព័ន្ធនឹងភាពយឺតយ៉ាវ និងភាពស្មុគស្មាញទាំងឡាយក្នុងដំណើរការរៀបចំឯកសារដែលពាក់ព័ន្ធជាមួយក្រសួងចំនួន ៣ក្នុងដំណាក់កាលនីមួយៗ។[31][32] ដោយហេតុនេះ ទើបធ្វើឲ្យពុំសូវមានសហគមន៍ជនជាតិដើមចង់ចុះបញ្ជីដីសមូហភាពសហគមន៍។ ក្នុងន័យនេះ គេគួរតែមានការពិនិត្យមើលឡើងវិញនូវនីតិវិធីផ្សេងៗ និងធ្វើឲ្យមានលក្ខណៈងាយស្រួលចំពោះដំណើរការ។

បញ្ហាទី២ គឺសហគមន៍ជនជាតិដើមភាគតិចអះអាងទំហំដីសហគមន៍ រួមមានដីព្រៃអារក្ស និងដីព្រៃកប់ខ្មោចធំលើសពីការកំណត់។ អនុក្រឹត្យ ៨៣ មាត្រា ៦ (ស្តីពី នីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច) ចែងថាទំហំដីអតិបរមាសម្រាប់ដីព្រៃអារក្ស ឬដីកប់ខ្មោចរបស់សហគមន៍នីមួយៗមានតែ ៧ហិចតាប៉ុណ្ណោះ។[33] ប៉ុន្តែតាមស្ថានភាពជាក់ស្តែង សហគមន៍ជនជាតិដើមមួយចំនួនបានទាមទារដីរាប់រយហិចតាចំពោះដីព្រៃអារក្ស និងដីព្រៃកប់ខ្មោច។[34] នេះបានបង្កជាបញ្ហាដែលបណ្ដាលឲ្យមានភាពយឺតយាវក្នុងដំណើរការចុះបញ្ជីកម្មសិទ្ធិដីសមូហភាព។ ដើម្បីឲ្យបញ្ហានេះកាន់តែមានភាពធូរស្រាលជាបន្តបន្ទាប់ គួរមានការរៀបចំសកម្មភាពបណ្តុះបណ្តាលផ្សេងៗដើម្បីឲ្យប្រជាពលរដ្ឋបានយល់ដឹងកាន់តែប្រសើរឡើង ពាក់ព័ន្ធនឹងនីតិវិធីចុះបញ្ជីកម្មសិទ្ធិដីសមូហភាព។

បញ្ហាប្រឈមចម្បងមួយទៀត គឺទំនាស់រវាងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច និងប្រជាពលរដ្ឋសហគមន៍ជនជាតិដើមភាគតិច។ នេះដោយសារតែ អនុក្រឹត្យ ៨៣ ចែងថា ការចុះបញ្ជីដីធ្លីអាចប្រព្រឹត្តិទៅបាន លុះត្រាតែគ្មានជម្លោះដីធ្លីកើតឡើង។[35] ជាញឹកញាប់ ជម្លោះដីធ្លីតែងកើតមានឡើង រវាងប្រជាពលរដ្ឋសហគមន៍ជនជាតិដើមភាគតិច និងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច។[36] គួរបញ្ជាក់ថា ដើម្បីពន្លឿនការចុះបញ្ជី គួរត្រួតពិនិត្យលើជម្លោះដីធ្លី និងដោះស្រាយឲ្យបានកាន់តែឆាប់រហ័ស។ ការដោះស្រាយវិវាទក៏អាចធ្វើទៅបាន តាមរយៈការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផងដែរ។[37]

## ៤. សន្និដ្ឋាន

ជារួម មានគោលនយោបាយ និងច្បាប់ល្អៗ ពាក់ព័ន្ធនឹងការអភិវឌ្ឍជនជាតិដើមភាគតិច។ ដំណើរការនៃការចុះបញ្ជីដីសមូហភាពសម្រាប់ជនជាតិដើមភាគតិចមានសន្ទុះកើនឡើង បន្ទាប់ពីការចាប់ផ្តើមអនុវត្តបទបញ្ញា០១ បើទោះបីជាមានសហគមន៍ជនជាតិដើមភាគតិចមួយចំនួនតូចទទួលបានកម្មសិទ្ធិដីធ្លីសមូហភាពនេះក៏ដោយ។ បញ្ហាប្រឈមមួយចំនួនបានកើតឡើង ក្នុងដំណើរការចុះបញ្ជីដីធ្លីសមូហភាពនេះ រួមមាន៖ ១) ភាពយឺតយូរ និងស្មុគស្មាញក្នុងដំណើរការចុះបញ្ជីដីធ្លីសមូហភាព ២) ការអះអាងដីព្រៃអារក្ស និងដីព្រៃកប់ខ្មោចធំលើសពីការកំណត់ក្នុងអនុក្រឹត្យ៨៣ របស់សហគមន៍ ៣) និងជម្លោះរវាងសហគមន៍ និងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច។ ដើម្បីឆ្លើយតបនឹងបញ្ហាទាំងនេះ គេគួរមានដំណោះស្រាយមួយចំនួនដូចខាងក្រោម៖

១) ពិនិត្យមើលទៅលើនីតិវិធីដែលកំពុងប្រើប្រាស់ក្នុងដំណើរការចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិច និងបង្កលក្ខណៈឲ្យមានភាពងាយស្រួលជាងមុន

២) ផ្តល់ការអប់រំបន្ថែមទៅលើនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ ដែលអាចធ្វើឡើងជាទៀងទាត់នៅក្នុងទីតាំងរបស់សហគមន៍ជនជាតិដើមភាគតិច

៣) ពិនិត្យមើលទៅលើករណីជម្លោះផ្សេងៗ និងដោះស្រាយឲ្យបានឆាប់រហ័សតាមតែអាចធ្វើទៅបាន។ ជម្លោះទាំងនោះ អាចដោះស្រាយបានតាមនីតិវិធីដែលមានស្រាប់ផ្សេងៗ និងក្រៅប្រព័ន្ធតុលាការ។

# ឯកសារយោង

[1] NIS 2007. General Population Census of Cambodia, 2008 *In:* NATIONAL INSTITUTE OF STATISTICS (ed.). Phnom Penh, Cambodia: Ministry of Planning.
[2] NCDD 2014. Commune Database 2014. *In:* INTERIOR, M. O. (ed.). Phnom Penh, Cambodia.
[3] ALISON, R. 2013. Directive 01BB in Ratanakiri Province, Cambodia:
Issues and impacts of private land titling in indigenous communities.
[4] NGO FORUM ON CAMBODIA 2006. INDIGENOUS PEOPLES IN CAMBODIA
[5] ALISON, R. 2013. Directive 01BB in Ratanakiri Province, Cambodia:
Issues and impacts of private land titling in indigenous communities.
[6] This briefing note has been written in response to the Regional Group 8 of the Senate of Cambodia, as a key document for its mission scheduled to be early April 2016 to Ratanakiri province.
[7] Article 31 of the constitution stipulated that "the Constitution guarantees all citizens the same rights *regardless of race, color, sex, language… religious belief or other differences.* "
[8] RGC 2001a. Land Law 2001. Phnom Penh, Cambodia.
[9] MINISTRY OF RURAL DEVELOPMENT 2009a. National Policy on the Development of Indigenous People Phnom Penh, Cambodia: Ministry of Rural Development,.
[10] RGC 2001b. Land Law 2001. Phnom Penh, Cambodia., p. 1409. Article 23
[11] Ibid., Article25 & 26
[12]Ibid., Article 26
[13] MINISTRY OF RURAL DEVELOPMENT 2009a. National Policy on the Development of Indigenous People Phnom Penh, Cambodia: Ministry of Rural Development,.p.2
[14] Ibid., pp. 9-10
[15] RGC 2009a. Sub-Decree on Procedures of Registration of Land of Indigenous Communities. *83 ANK,BK.* Phnom Penh, Cambodia: Royal Government of Cambodia (article 6)
[16] CCHR 2016. Access to Collective Land Titles for Indigenous Communities in Cambodia,. Phnom Penh, Cambodia.
[17] RGC 2009a. Sub-Decree on Procedures of Registration of Land of Indigenous Communities. *83 ANK,BK.* Phnom Penh, Cambodia: Royal Government of Cambodia
[18]MINISTRY OF RURAL DEVELOPMENT 2016. Intervention Report on the Management and Rural Development Programme in Rattanakiri Province. Phnom Penh, Cambodia: Department of Rural Development.
[19] MINISTRY OF PLANNING 2014. CDB National Data 2014. *In:* MINISTRY OF PLANNING (ed.). Phnom Penh, Cambodia.
[20]Ibid.
[21] ILO 2015. Update List of Collective Land Titling Progress with Support of ILO, GIZ and NGO and Target Affected by Directive 01 from 2003-13/01/2015. Phnom Penh.
[22]GIZ. 2013. *GIZ's indigenous community land registration initiative ranks as largest effort to secure indigenous land rights in Cambodia* [Online]. Phnom Penh, Cambodia: GIZ. Available: http://giz-cambodia.com/gizs-indigenous-community-land-registration-initiative-ranks-as-largest-effort-to-secure-indigenous-land-rights-in-cambodia/ [Accessed 22 March 2015].
[23]RGC 2012a. Directive on measure to strengthen and foster effectiveness of ELC management. Phnom Penh.
[24]RGC 2012b. Instruction #15 on the implementation of RGC's directive 01BB issued on 07 May 2012 on "measure to strengthen and foster effectiveness of ELC management" related to indigenous community's areas, forest areas, military-based areas and historical-cultural heritage Phnom Penh, RGC 2012c. Instruction #17 on the implementation of RGC's directive 01BB issued on 07 May 2012 on "measure to strengthen and foster effectiveness of ELC management" related to land road, railway, path, stream, river, beach and public service areas. Phnom Penh.
[25]Information provided during meeting of Technical Working Group on Land, 16 October 2014, and the minute was taken and shared by the NGO Forum, and finally cited in MARK, G. & LAURA, S. 2015. New actions and existing policies: the implementation and impacts of Order 01 Phnom Penh: The NGO Forum on Cambodia.

[26]ILO 2015. Update List of Collective Land Titling Progress with Support of ILO, GIZ and NGO and Target Affected by Directive 01 from 2003-13/01/2015. Phnom Penh.
[27]CCHR 2016. Access to Collective Land Titles for Indigenous Communities in Cambodia,. Phnom Penh, Cambodia.
[28]Ibid. p.20
[29] ILO 2015. Update List of Collective Land Titling Progress with Support of ILO, GIZ and NGO and Target Affected by Directive 01 from 2003-13/01/2015. Phnom Penh.
[30]Ibid.
[31]CCHR 2016. Access to Collective Land Titles for Indigenous Communities in Cambodia,. Phnom Penh, Cambodia.
[32] PRACHVUTHY, M. 2011. Land acquistion by non-local actors and consequences for local development: Impacts of economic land concessions on the livelihoods of indigenous communities in northeast provinces of Cambodia
[33]RGC 2009a. Sub-Decree on Procedures of Registration of Land of Indigenous Communities. *83 ANK,BK.* Phnom Penh, Cambodia: Royal Government of Cambodia
[34] PRACHVUTHY, M. 2011. Land acquistion by non-local actors and consequences for local development: Impacts of economic land concessions on the livelihoods of indigenous communities in northeast provinces of Cambodia
[35] RGC 2009b. Sub-decree on procedures of registration of land of indigenous communities Phnom Penh.
[36]PRACHVUTHY, M. 2011. Land acquistion by non-local actors and consequences for local development: Impacts of economic land concessions on the livelihoods of indigenous communities in northeast provinces of Cambodia
[37]RGC 2014. National Strategic Development Plan 2014-2018. Phnom Penh, Cambodia: Ministry of Planing